# សុន្ទរកថារបស់**លោក ហ៊ីហ្គូជិ យ៉ូស៊ីហ៊ីរ៉ូ**

## ភារៈធារីស្តីទីស្ថានទូតជប៉ុនប្រចាំព្រះរាជាណាចក្រកម្ពុជា
## ថ្លែងក្នុងពិធីចុះហត្ថលេខាលើកិច្ចសន្យាផ្តល់ជំនួយ
## សម្រាប់គម្រោងទ្រង់ទ្រាយតូចសន្តិសុខមនុស្សជាតិ របស់ប្រទេសជប៉ុន

០១ មិនា ២០១៣

**សូមគោរព លោកវេជ្ជបណ្ឌិត Glyn Vaughan ប្រធានអង្គការសុខភាពត្រចៀកនៅកម្ពុជា!**
**សូមគោរព អស់លោក លោកស្រី!**

ខ្ញុំមានសេចក្តីសោមនស្សរីករាយដើម្បីចុះហត្ថលេខាលើកិច្ចសន្យាផ្តល់ជំនួយសម្រាប់គម្រោងបំពាក់ឧបករណ៍ពិនិត្យ និងព្យាបាលប្រព័ន្ធសោតវិញ្ញាណក្នុងរាជធានីភ្នំពេញជាមួយតំណាងរបស់អង្គការសុខភាពត្រចៀកនៅកម្ពុជា ដែលបាននិងកំពុងផ្តល់ដំណោះស្រាយផ្នែកការស្តាប់របស់ប្រជាជនកម្ពុជាតាំងពីឆ្នាំ២០០៣មក។ ខ្ញុំក៏មានសេចក្តីសោមនស្សរីករាយជាពិសេសដែលការចុះហត្ថលេខានេះត្រូវបានធ្វើឡើងក្នុងឱកាសដ៏ពិសេសនៃឆ្នាំ២០១៣ដែលជាខួបអនុស្សាវរីយ៍ទី៦០នៃទំនាក់ទំនងមិត្តភាពជប៉ុន-កម្ពុជា។

គម្រោងនេះមានគោលដៅកែលម្អការផ្តល់សេវាផ្នែកសុខភាពត្រចៀករបស់គ្លីនិកអង្គការសុខភាពត្រចៀកនៅកម្ពុជាក្នុងរាជធានីភ្នំពេញដោយការបំពាក់ឧបករណ៍ពិនិត្យ និង ព្យាបាលប្រព័ន្ធសោតវិញ្ញាដែលរួមមានឧបករណ៍បញ្ចាំងភ្លើងហ្វា និងបន្ទប់ធ្វើតេស្តន៍ការស្តាប់សម្លេង។ ថវិកាជំនួយសរុបសម្រាប់គម្រោងនេះមានចំនួន៩១,៤២៩ដុល្លាអាមេរិក។ យើងរំពឹងថា គម្រោងនេះនឹងផ្តល់អត្ថប្រយោជន៍ដល់ប្រជាជនប្រមាណ២,០០០នាក់ដែលមានបញ្ហាផ្នែកការស្តាប់ដោយសារបុគ្គលិកគ្លីនិកនឹងអាចធ្វើរោគវិនិច្ឆ័យទៅលើប្រព័ន្ធសោតវិញ្ញាណកាន់តែច្បាស់ ព្រមទាំងផ្តល់ការព្យាបាលកាន់តែត្រឹមត្រូវ។ ជាងនេះទៅទៀត យើងរំពឹងថាការកែលម្អសេវាសុខភាពត្រចៀកដែលផ្តល់ដោយគ្លីនិកនេះនឹងរួមចំណែកលើកស្ទួយភាពម្ចាស់ការផ្នែកសេដ្ឋកិច្ច និង សង្គមកិច្ចរបស់អ្នកជំងឺត្រចៀកនៅពេលដែលពួកគេអាចទទួលបានឱកាសទៅសិក្សានៅតាមសាលា និងបំពេញការងារនានា។

ការអភិវឌ្ឍវិស័យសុខាភិបាលមានសារៈសំខាន់ណាស់សម្រាប់ការកែលម្អគុណភាពជីវិតនៃប្រជាជនកម្ពុជា។ ដោយទទួលស្គាល់ពីតួនាទីសំខាន់នៃវិស័យសុខាភិបាល រដ្ឋាភិបាលជប៉ុនបានផ្តល់អាទិភាពខ្ពស់ទៅលើជំនួយផ្នែកសុខាភិបាលដែលរួមមានការសាងសង់ហេដ្ឋារចនាសម្ព័ន្ធសុខាភិបាលសាធារណៈ ការផ្តល់សម្ភារៈបរិក្ខារពេទ្យ និងការគាំទ្រដល់ការពង្រឹងសមត្ថភាពអ្នកជំនាញសុខាភិបាលជាដើម។ ខ្ញុំមានជំនឿថា គម្រោងថ្មីនេះក៏នឹងជួយលើកស្ទួយសន្តិសុខមនុស្សជាតិសម្រាប់ប្រជាជនងាយរងគ្រោះដែលមានបញ្ហាផ្នែកការស្តាប់ដោយពួកគេអាចទទួលបានសេវាថែទាំ និងព្យាបាលសោតវិញ្ញាណពីអង្គការសុខភាពត្រចៀកនៅកម្ពុជា។

ខ្ញុំសង្ឃឹមថាគម្រោងដែលចុះហត្ថលេខាថ្ងៃនេះនឹងត្រូវបានអនុវត្តដោយរលូន និង ប្រសិទ្ធភាព ព្រមទាំងថែទាំយ៉ាងត្រឹមត្រូវដោយដៃគូរបស់យើងគឺអង្គការសុខភាពត្រចៀកនៅកម្ពុជា ដើម្បីអ្នកជំងឺកាន់តែច្រើននាពេលអនាគតអាចទទួលបានអត្ថប្រយោជន៍ពីគម្រោងនេះ។

ជាចុងក្រោយនេះ ខ្ញុំសង្ឃឹមថាកិច្ចសហប្រតិបត្តិការនេះនឹងជួយពង្រឹងជាបន្តទៅទៀតនូវទំនាក់ទំនងមិត្តភាពរវាងប្រជាជនជប៉ុន និង ប្រជាជនកម្ពុជា។

សូមអរគុណ!